ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខុទ្ទកាល័យ
លេខ 3119
ថ្ងៃទី 05.07.24
4096
9.7.24

លេខ......១០៦......ន-សផក

ថ្ងៃពុធ ១២ កើត ខែ អាសាឍ ឆ្នាំរោង ឆស័ក ព .ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០២៤

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ:** របាយការណ៍កែលម្អតាមអនុសាសន៍បានផ្តល់ឱ្យសម្រាប់ការិយបរិច្ឆេទ២០២២ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកែប

**យោង:** -ផែនការសវនកម្មផ្ទៃក្នុងនិងផែនការតាមដានអនុសាសន៍ប្រចាំឆ្នាំ២០២៤ លេខ១១២០ ដនស/នា.សផក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-លិខិតបញ្ជាបេសកកម្មលេខ ១១៧៤,១១៧៧ ដនស ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពអនុញ្ញាតជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ប្រតិភូសវនករបានចុះពិនិត្យការកែលម្អតាមអនុសាសន៍សវនកម្មផ្ទៃក្នុង នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**ខេត្តកែប** ដែលប្រតិភូសវនករផ្តល់ឱ្យសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ ការអង្កេតរកឃើញរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចុះពិនិត្យការងារលទ្ធកម្មសម្រាប់ការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធបានផ្តល់អនុសាសន៍ដូចខាងក្រោម÷

**ក.អនុសាសន៍របស់សវនកម្មផ្ទៃក្នុង÷**

១.មន្ទីរត្រូវគ្រប់គ្រងបញ្ជីវត្តមានឱ្យបានត្រឹមត្រូវ ស្របតាមអនុក្រឹត្យលេខ០៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។

២.មន្ទីរត្រូវពង្រឹងការងាររដ្ឋបាលលើផ្នែកចុះលេខលិខិត នៅក្នុងសៀវភៅចុះលេខលិខិតចូលឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។

៣.មន្ទីរត្រូវតម្រូវឱ្យមន្ត្រីដែលចុះបំពេញបេសកកម្ម រាយការណ៍លទ្ធផលការងារនៅលើលិខិតទិដ្ឋាការសម្រាប់ការទូទាត់បេសកកម្មឱ្យបានគ្រប់ចំនួន។

៤.មន្ទីរត្រូវជំរុញការបើកប្រាក់រង្វាន់កម្រៃសេវាសាធារណៈជូនមន្ត្រីតាមគណនីធនាគារដើម្បីឱ្យស្របតាមសារាចរណែនាំលេខ០១២ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ និងសារាចរ ណែនាំលេខ០១៨ សហវ

ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្ដីពីការបើកគណនីរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលគណនី របស់រដ្ឋទេយ្យករបុរេប្រទាន គណនីរបស់រដ្ឋទេយ្យករចំណូល និងគណនីរបស់ភ្នាក់ងារបើកផ្ដល់នៅធនាគារ។

៥. មន្ទីរត្រូវបង់លេខកូដសម្គាល់លើសម្ភារការិយាល័យ បរិក្ខាបច្ចេកទេស និងគ្រឿងសង្ហារិមឱ្យបានរួចរាល់គ្រប់ចំនួន។

**ខ. ការអង្កេតរកឃើញរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷**

១. មន្ទីរពុំបានធ្វើតារាងប្រៀបធៀបទីផ្សារនៃសមាសធាតុលទ្ធកម្ម។

២. មន្ទីរពុំមានរបាយការណ៍តាមដានគម្រោងសំណង់។

៣. អ្នកម្ចាស់ការ(មន្ទីរ)ពុំបានចេញលិខិតបញ្ជាក់ការបញ្ចប់ការងារសំណង់។

ឆ្លងតាមការពិនិត្យតាមអនុសាសន៍បានផ្ដល់ឱ្យខាងលើនិងការបំភ្លឺបង្ហាញថា អង្គភាពរងសវនកម្មបានយកចិត្តទុកដាក់ក្នុងការកែលម្អនិងបានលទ្ធផលដូចខាងក្រោម÷

**ក. ការឆ្លើយតបចំពោះអនុសាសន៍សវនកម្មផ្ទៃក្នុង÷**

១. មន្ទីរបាន និងកំពុងពង្រឹងបញ្ជីវត្តមានមន្ត្រីឱ្យស្របតាមអនុក្រឹត្យលេខ០៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។

២. មន្ទីរបានអនុវត្តការងាររដ្ឋបាលលើផ្នែកចុះលេខលិខិតនៅក្នុងសៀវភៅចុះលេខលិខិតចូល បានល្អប្រសើរប៉ុន្តែក៏នៅមានការចុះលេខស្ទួនមួយចំនួន។

៣. ការចុះបំពេញបេសកកម្ម មន្ទីរបានភ្ជាប់របាយការណ៍លទ្ធផលការងារនៅលើលិខិតទិដ្ឋាការសម្រាប់ការទូទាត់រួចហើយ។

៤. មន្ទីរបានបញ្ចូលប្រាក់រង្វាន់កម្រៃសេវាសាធារណៈជូនមន្ត្រីតាមគណនីធនាគាររបស់មន្ត្រី ចាប់តាំងពីដើមឆ្នាំ២០២៤ មក។

៥. មន្ទីរបានធ្វើទំនាក់ទំនងជាមួយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកែប ដើម្បីបង់លេខកូដសម្គាល់លើសម្ភារការិយាល័យ បរិក្ខាបច្ចេកទេស និងគ្រឿងសង្ហារិម ឱ្យស្របតាមនីតិវិធី។

**ខ. ការឆ្លើយតបចំពោះការអង្កេតរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈរបស់ក្រសួង ស.ហ.វ÷**

១. មន្ទីរបានអនុវត្តតាមនីតិវិធីលទ្ធកម្មដេញថ្លៃក្នុងស្រុក ដោយមានឯកសារដេញថ្លៃ និងតម្លៃប៉ាន់ស្មានគម្រោងចូលរួមចំនួន០៣ ក្រុមហ៊ុន។

២. មន្ទីរនឹងអនុវត្តឱ្យមានរបាយការណ៍តាមដានគម្រោងសំណង់។

៣. មន្ទីរមានកំណត់ហេតុប្រគល់ ទទួលការងារសាងសង់/ជួសជុលថែទាំ និងពង្រីកអគាររវាងមន្ទីរ និងអ្នកម៉ៅការសំណង់ ដែលបានបញ្ជាក់ពីការងារសាងសង់បានបញ្ចប់១០០% ហើយ។

ទន្ទឹមនឹងនោះក៏នៅមានចំណុចសេសសល់ និងខ្វះខាតបន្តិចបន្តួចដែលមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកែប នឹងធ្វើការកែលម្អបន្ថែមទៀត ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងមានមតិដឹកនាំដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

**ប្រធាននាយកដ្ឋាន**

**យួន_សុជាតិ**

| **មតិឯកឧត្តមរដ្ឋលេខាធិការប្រចាំការ** | **មតិឯកឧត្តមប្រធានក្រុមការងារ** |
| --- | --- |
| 04.07.24 | 04/7/24 |

**មតិសម្រេចឯកឧត្តមឧបនាយករដ្ឋមន្ត្រី**